ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ភ្នំពេញ

**********

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧០០

ចុះថ្ងៃទី ១៩_១១_២០០៩

សាលដីកា

លេខ : ១០៦ "ខ"

ចុះថ្ងៃទី ២២_១០_២០១០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១០_២០១០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ៧០០ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានៈ

១- ជនជាប់ចោទឈ្មោះ [redacted]**គេង ហៅ កុយ** ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ១១ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃ[redacted]ាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted] "រ" នៅលីវ ទោសពីមុនគ្មាន។

ឃុំខ្លួនថ្ងៃទី ០៧-០៨-២០០៩ បច្ចុប្បន្ននៅក្រៅឃុំ។

មានមេធាវីការពារ លោក [redacted]**ហាក់ និងលោក** [redacted] **សុខុន**។

**ជាប់ចោទពីបទៈ** ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- ជនជាប់ចោទឈ្មោះ [redacted]**គីមអៀង** ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះជួល សង្កាត់ទន្លេ[redacted] ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted] "រ" ប្តីឈ្មោះ[redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។

**ជាប់ចោទពីបទ:** ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥០៦ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] **កេង ហៅ កុយ** ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៥ "ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី ០៤-០២-២០០៩ វេលាម៉ោង ១៧ កំលាំងមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបករណីចែកចាយគ្រឿងញៀនមួយកន្លែងនៅតាមផ្លូវមុន្នីរ៉េត ត្រង់ចំណុចគល់ស្ពានស្ទឹងមានជ័យ ហើយបានឃាត់ខ្លួនជនម្នាក់ឈ្មោះ [redacted] **គីមអៀង ហៅ ម៉ាប់** ពេលដែលជននោះកំពុងធ្វើការចែកចាយគ្រឿងញៀន និងបានដកហូតវត្ថុតាង គ្រឿងញៀនប្រភេទម្សៅទឹកកក ចំនួនមួយកញ្ចប់ ទំងន់ ០១ក្រាម ដែលជននោះបានទិញពីឈ្មោះ **កុយ** ភេទប្រុស។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៩៥ "ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោម:**

១- កែប្រែបទល្មើសដែលចោទប្រកាន់លើឈ្មោះ [redacted] **គីមអៀង** ហៅ **ម៉ាប់** ភេទស្រី អាយុ ៣៥ឆ្នាំ ពីបទចែកចាយគ្រឿងញៀនខុសច្បាប់ បញ្ញត្តិផ្តន្ទាទោសមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលសម្រេចចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២៣២ អយ.ខ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១ ១៧៦តព្រ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ មកជាបទ ជួញដូរគ្រឿងញៀនខុសច្បាប់ បញ្ញត្តិផ្តន្ទាទោសមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២- ក- ផ្តន្ទាទោសលើឈ្មោះ[redacted] **គីមអៀង ហៅ ម៉ាប់** ភេទស្រី អាយុ ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៩

ខ- ផ្តន្ទាទោសលើឈ្មោះ [redacted] **កេង ហៅ កុយ** ភេទប្រុស អាយុ ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩

ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣- វត្ថុតាង គឺ គ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះមេតំហ្វេតាមីន ចំនួនមួយកញ្ចប់ ទម្ងន់មួយក្រាម មានកម្រិតភាពសុទ្ធ ៨៥.៨ ភាគរយ នៃទម្ងន់សរុប ត្រូវរឹបអូសបំផ្លាញចោល។

តាមមាត្រា ៨៥ ថ្មី នៃច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤- សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ ។

បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៥០៦ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] កេង ហៅ កុយ ជាជនជាប់ចោទ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] កេង ឆ្លើយថាៈ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយតាំងពីដើមមក ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] គឹមអៀង ទេ ពេលប៉ូលីសចាប់។ខ្លួនតែម្នាក់ឯងទេ ។ ដូច្នេះ សូមតុលាការមេត្តាលើកលែងចោទប្រកាន់ឱ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] គឹមអៀង ឆ្លើយថាៈ ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ កុយ នៅមុខវត្ត តែឈ្មោះ កុយ អាយុ ១៨ឆ្នាំ មិនមែនឈ្មោះ [redacted] កេង ទេ ។ ពេលប៉ូលីសចាប់។ខ្លួនតែម្នាក់ឯងទេ ប្រាំពីរខែក្រោយទើបប៉ូលីសចាប់ឈ្មោះ [redacted] កេង នេះ ហើយផ្ទះដែលខ្លួនទាក់ទងទិញថ្នាំនៅគល់ស្ពានស្ទឹងមានជ័យ គឺផ្ទះឈើមួយជាបន្ទប់។ ។ សំណូមពរសុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្ដាប់របាយការណ៍ ក្រោយពីបានពិនិត្យសំណុំរឿង ឯកសារពាក់ព័ន្ធ និងស្ដាប់ការសួរដេញដោល តំណាងមហាអយ្យការកត់សម្គាល់លើភស្ដុតាងខ្លះមិនស៊ីសង្វាក់ពិតមែន តែការឆ្លើយដោះសាររបស់ឈ្មោះ [redacted] គឹមអៀង ថា ឈ្មោះ [redacted] កេង ហៅ កុយ គឺក្មេងមិនមែន [redacted] កេង ហៅ កុយ នៅសវនាការនេះទេ ក្នុងរឿងនេះតំណាងមហាអយ្យការសុំឱ្យក្រុមប្រឹក្សាពិចារណាទៅលើបទចោទលើឈ្មោះ [redacted] កេង ហៅ កុយ ដើម្បីជាផលប្រយោជន៍តាមច្បាប់ និងមានលក្ខណៈទូទៅ ដូច្នេះ សូមពិចារណាឡើងវិញ ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

កូនក្ដីខ្លួនឈ្មោះ [redacted] កេង មិនដែលមានទំនាក់ទំនងជាមួយឈ្មោះ [redacted] គឹមអៀង ទេ ប៉ូលីសបានចាប់ឈ្មោះ [redacted] គឹមអៀង នៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩ មានរយៈពេល ៦ខែ ទើបចាប់កូនក្ដីខ្លួន ហើយឈ្មោះ [redacted] គឹមអៀង គាត់បានឆ្លើយថា គាត់បានទិញថ្នាំពីឈ្មោះ កុយ អាយុ ១៨ឆ្នាំ ហើយលេខទូរស័ព្ទដែលគាត់ប្រើក្នុងការប្រើប្រាស់ លេខទិញថ្នាំញៀនមានលេខ [redacted] រឿងនេះមិនបានបញ្ជាក់សាវតាជាតិច្បាស់លាស់ដើម្បីជាផលប្រយោជន៍

តាមច្បាប់ និងផលប្រយោជន៍កូនក្តីខ្លួនទេ។ ដូច្នេះ សូមប្រធានក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួន និងលុបចោលសាលក្រមរបស់សាលាដំបូងចោលជាអសារបង់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ដោយឈ្មោះ [redacted] កេង មានសាវតាជាតិគ្រប់គ្រាន់ និងយោងលើអង្គច្បាប់មាត្រា ១៣ ចៅក្រមអាចដោះលែងដោយភស្តុតាងមិនគ្រប់គ្រាន់ និងមាត្រា ២ ពាក្យសារភាពដែលបង្ខិតបង្ខំត្រូវទុកជាមោឃៈ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា៖

១- បណ្តឹងឧទ្ធរណ៍លេខ ៥០៦ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ ដាត់ កេង ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទថា ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] គីមអៀង ទេ ខ្លួនមានរបររកស៊ីជួសជុលទូរស័ព្ទ មិនដែលធ្លាប់រកស៊ីជួញដូរគ្រឿងញៀនទេ។

- ប៉ុន្តែតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] គីមអៀង ថា ខ្លួនធ្លាប់រកស៊ីចែកចាយគ្រឿងញៀន ដោយទាក់ទងនឹងឈ្មោះ កុយ ([redacted] កេង) ជាជនជាប់ចោទ គឺនៅពេលណាមានគេត្រូវការរកទិញ ខ្លួនទៅទាក់ទងទិញពីឈ្មោះ កុយ។ នៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ កុយ យកទៅឱ្យឈ្មោះ បូ មែន។

៣- តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀន លេខ ៤៧០/០៩ មពអជបគញ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៩ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន វត្ថុតាងជាគ្រឿងញៀន មានទម្ងន់សរុប ចំនួន ០១ក្រាម មានកម្រិតធាតុសុទ្ធស្មើនឹង ០,៨៥៨ក្រាម។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧-៤ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដូច្នេះ គួរកែប្រែឡើងវិញ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ សម្រេចមានលក្ខណៈត្រឹមត្រូវ ត្រូវតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្ម និងអត្ថបទច្បាប់ គួរកែប្រែដូចយល់ឃើញខាងលើវិញ ក្រៅពីនេះត្រូវទុកនៅដដែល។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥០៦ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] កេង ហៅ កុយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មត្រូវកែជា ១៦ខែ តាមមាត្រា ៣៧-៤ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញ ក្រៅពីនេះទុកនៅដដែល ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ។

បើកផ្លូវសាទុក្ខ ០១ខែគិតចាប់ពីថ្ងៃនេះទៅ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ៕**

**ក្រឡាបញ្ជី**
ហត្ថលេខា:
[redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា:
[redacted], [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា:
[redacted]

---

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 30 ខែ 12 ឆ្នាំ២០១០
**ក្រឡាបញ្ជី**

[redacted]